# សូមទាក់ទងទៅសាលារដ្ឋដែលនៅតាមតំបន់របស់លោកអ្នក

## ការចុះឈ្មោះចូលរៀននៅថ្នាក់មត្តេយ្យ

## ថ្ងៃទី២០ ខែមករា ដល់ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥

## ចុះឈ្មោះកូនរបស់លោកអ្នកពីឥឡូវនេះ សម្រាប់ ខែកញ្ញា ឆ្នាំ២០១៥!

## ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា



**កូនរបស់លោកអ្នកត្រូវមានអាយុ៥ឆ្នាំ មុន ឬនៅថ្ងៃ ទី១ ខែកញ្ញា ឆ្នាំ២០១៥**

**សូមទៅសាលាដែលនៅតាមតំបន់របស់លោកអ្នក ហើយកុំភ្លេចយកសំបុត្រទាំងនេះទៅជាមួយផង៖**

- ✓ ឯកសារចាក់ថ្នាំបង្ការរោគតាមកំណត់ របស់កូនលោកអ្នក
- ✓ អត្តសញ្ញាណប័ណ្ណរបស់ មាតាបិតា/អាណាព្យាបាល៖ ប័ណ្ណបើកបរថ្មីៗ/អត្តសញ្ញាណប័ណ្ណមិនមែនសម្រាប់បើកបរ ប័ណ្ណធ្វើការនៅរដ្ឋសហព័ន្ធ រដ្ឋ ឬទីក្រុង ឬលិខិតឆ្លងដែន

**ត្រូវការឯកសារមួយ ក្នុងចំណោមឯកសារទាំងនេះ៖**

- ✓ សំបុត្រកំណើតរបស់កូន
- ✓ ច្បាប់ចម្លងនៃសំបុត្រកំណើតរបស់ក្មេង ដែលមានបោះត្រាបញ្ជាក់
- ✓ លិខិតឆ្លងដែនរបស់ក្មេងដែលមានសុពលភាព
- ✓ សំបុត្រលាងបាប ដែលបញ្ជាក់ថ្ងៃកំណើតរបស់ក្មេង
- ✓ ច្បាប់ចម្លងនៃសំបុត្រលាងបាប – ត្រូវមានបោះត្រា ឬមានការបញ្ជាក់ត្រឹមត្រូវ និងបង្ហាញពីថ្ងៃកំណើត
- ✓ ការសរសេរបញ្ជាក់ពី មាតាបិតា ឬសាច់ញ្ញាតិដ៏ទៃទៀត ដែលបង្ហាញថ្ងៃកំណើត ត្រូវមានបោះត្រាបញ្ជាក់
- ✓ សំណុំឯកសារសាលាពីមុន ដែលបង្ហាញពីថ្ងៃកំណើត

**ហើយ**

សូមកុំភ្លេចយកភ័ស្តុតាងពីរ ដែលបង្ហាញពីអាស័យដ្ឋានរស់នៅសព្វថ្ងៃ ដែលមានឈ្មោះមាតាបិតា ឬអាណាព្យាបាល។ សាលានឹងសុំមើល**ភ័ស្តុតាងពីរ** ដែលបង្ហាញពីអាស័យដ្ឋានរស់នៅ។

- ✓ ប័ណ្ណកម្មសិទ្ធ
- ✓ សំបុត្រកាត់ឈ្មោះផ្ទះ
- ✓ សំបុត្របង់ថ្លៃ (ភ្លើង ហ្គែស ខ្សែកាប ទូរស័ព្ទ)
- ✓ វិក្កយប័ត្របង់ពន្ធផ្ទះ ថ្មីៗ
- ✓ ប័ណ្ណបើកបរ ឬប័ណ្ណដូរអាស័យដ្ឋាន ដែលមានអាស័យដ្ឋានបច្ចុប្បន្ន
- ✓ លិខិតពី ការិយាល័យសូស្យល់សិខ្យូរីធី ដែលមានអាស័យដ្ឋានបច្ចុប្បន្ន
- ✓ លិខិតពី ការិយាល័យផ្តល់ប្រាក់ជំនួយ ដែលមានអាស័យដ្ឋានបច្ចុប្បន្ន
- ✓ គេទទួលលិខិតពី អ្នកចិញ្ចឹមក្មេង/មើលថៃក្មេង និងអង្គការ DHS សម្រាប់ការ ចុះឈ្មោះនៅពេលដែលសិស្សស្ថិតនៅក្រោមការមើលថៃរបស់អង្គការ ចិញ្ចឹមក្មេង/មើលថៃក្មេង
- ✓ កិច្ចព្រមព្រៀងជួលផ្ទះដែលមានឈ្មោះ មាតាបិតា/អាណាព្យាបាល និងក្មេង
- ✓ អត្តសញ្ញាណប័ណ្ណដែលមានសុពលភាពពីក្រសួងយានជំនិះ
- ✓ វិក្កយប័ត្រឥណទានថ្មីៗ
- ✓ ប័ណ្ណសម្គាល់រថយន្តថ្មីៗ
- ✓ ប័ណ្ណសម្រាប់បោះឆ្នោត ដែលបង្ហាញអាស័យដ្ឋាន**បច្ចុប្បន្ន**
- ✓ របាយការណ៍គណនីពីធនាគារថ្មីៗ ដែលមានអាស័យដ្ឋានបច្ចុប្បន្ន
- ✓ លិខិតបង្ហាញចំនួនប្រាក់ពី IRS ឬ ប្រាក់ខែ និងពន្ធ ផ្សេងៗ ដូចជា W2, 1040, 1099
- ✓ កន្ទុយសែកពីកន្លែងធ្វើការថ្មីៗ បង្ហាញពីអាស័យដ្ឋានបច្ចុប្បន្ន
- ✓ គេទទួលលិខិតពីកន្លែងជ្រកកោនសម្រាប់សិស្សានុសិស្សដែលគ្មានលំនៅ
- ✓ ឯកសារលក់ផ្ទះដែលបានចុះហត្ថលេខារួច ព្រមទាំងឯកសារច្បាប់ដើមនៃការកាត់ឈ្មោះផ្ទះ ក្នុងកំឡុងពេល ៤៥ថ្ងៃ ចាប់ពីថ្ងៃកាត់ឈ្មោះ

លោកអ្នកនិងកូនអាចទៅមើលថ្នាក់មត្តេយ្យជាមុនសិន ដោយទៅមើលសាលាដែលនៅតាមតំបន់របស់លោកអ្នក ក្នុងពេល

**ដើរមើលថ្នាក់មត្តេយ្យ**

**ថ្ងៃដើរមើលថ្នាក់មត្តេយ្យ៖ ថ្ងៃពុធ ទី៤ ខែមីនា ឆ្នាំ២០១៥**

**អាទិត្យដើរមើលថ្នាក់មត្តេយ្យ៖ ថ្ងៃទី១១ ដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥**

សូមទាក់ទងទៅសាលាដែលនៅតាមតំបន់របស់លោកអ្នក ដើម្បីសួរបញ្ជាក់អំពី ថ្ងៃ និង ម៉ោង នៅអាទិត្យនោះ

ដើម្បីស្វែងរកសាលាក្នុងតំបន់របស់លោកអ្នក សូមមើលវិបសៃ https://webapps.philasd.org/school_finder/km